ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សាលក្រមព្រហ្មទណ្ឌ
លេខៈ ១២៨ (ខ)
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្ដាល បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពៈ

**ក្រុមប្រឹក្សាជំនុំជំរះ**

-លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជំរះនៃសាលាដំបូងខេត្តកណ្ដាល
-លោក ចៅក្រមប្រឹក្សាជំនុំជំរះនៃសាលាដំបូងខេត្តកណ្ដាល
-លោក ចៅក្រមប្រឹក្សាជំនុំជំរះនៃសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**មេធាវី**

-លោកស្រី [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ ពៅ រីន ហៅចុង។

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៩៣៧ អ.ក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ លើជនជាប់ចោទឈ្មោះ៖

១-ឈ្មោះ [redacted] **ប៉េងឡាត់** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ឡុង (រស់), ម្ដាយឈ្មោះ [redacted] ឈឿន (រស់) នៅលីវ ទោសពីមុនគ្មាន។ (ឃុំខ្លួនថ្ងៃទី០៥/០៧/២២)

២.ឈ្មោះ [redacted] **រីន ហៅចុង** ភេទប្រុស អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ពៅ (រស់), ម្ដាយឈ្មោះ [redacted] សាវៃន (រស់) នៅលីវ ទោសពីមុន គ្មាន។ (ឃុំខ្លួនថ្ងៃទី០៥/០៧/២២)

ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

### អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ វេលាម៉ោង ២១និង០០នាទី ស្ថិតនៅចំណុចភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល មានករណីមួយបានកើតឡើង ដែលបង្ករឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត់ និងឈ្មោះ [redacted] រីន បានជិះម៉ូតូមួយគ្រឿង មកដល់ចំណុចកើតហេតុក៏បានជួបជាមួយ



Scanned with CamScanner

នឹងជនរងគ្រោះឈ្មោះ [redacted] ប៉េងស៊ាង ខណៈនោះជនជាប់ចោទឈ្មោះ [redacted]រ៉ែន បានហូតខ្សែក្រវ៉ាត់ចេញពីចង្កេះខោហើយវាយទៅលើជនរងគ្រោះត្រូវចំក្បាល បណ្តាលឲ្យបែកក្បាល ហើយជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត់ បានជិះម៉ូតូរត់គេចខ្លួនបាត់តែម្តង។ រួចជនរងគ្រោះក៏បានទៅដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលស្រុកស្អាង ឲ្យធ្វើការឃាត់ខ្លួនជនជាប់ចោទទាំងពីរបញ្ជូនមកតុលាការ ដើម្បីចាត់ការតាមនីតិវិធី។

## ឃ្មានឃើញ

-ដីកាសន្និដ្ឋានស្ថាពរលេខ: ៨៧៣ ដកសព ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-ដីកាដំណោះស្រាយលេខ: ៩០៥ ដកជស ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-ដីកាចាត់តាំងប្រធានក្រុមប្រឹក្សាជំនុំជម្រះលេខ: ៩៨៧ ដកចត ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ
ក្រោយពីបានពិនិត្យភស្តុតាងឯកសារទាំងអស់ក្នុងសំណុំរឿងស្រាប់
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ
ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

## សំអាងហេតុ

១-តុលាការទទួលពាក្យបណ្តឹងតាមដីកាដំណោះស្រាយលេខ: ៩០៥ ដកជស ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ប៉េងឡាត់** នឹងឈ្មោះ [redacted]**រ៉ែន ហៅចុង** មកតុលាការដើម្បីជំនុំជម្រះ ពីបទ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

២-តាមអង្គហេតុបានបង្ហាញថា កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ ស្ថិតនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល ពិតជាកើតមាននូវអំពើ ហិង្សាដោយចេតនា ប្រាកដមែន ដែលអំពើនេះប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត់ និងឈ្មោះ [redacted]រ៉ែន បានធ្វើសកម្មភាពជិះម៉ូតូដេញវាយតប់ទៅលើជនរងគ្រោះ បណ្តាលឲ្យជនរងគ្រោះរងរបួស ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត់ បានឆ្លើយថាៈ នៅថ្ងៃកើតហេតុ ខ្លួនជិះម៉ូតូមួយគ្រឿងជាមួយមិត្តភក្តិរបស់ខ្លួនឈ្មោះ [redacted]រ៉ែន ដើម្បីទៅមើលល្ខោនបាសាក់នៅវត្តចុងកោះ ពេលជិះម៉ូតូមកដល់ចំណុចកំពង់ដរដើមក្រឹង ឃុំកោះខែល ស្រាប់តែមានបុរសម្នាក់ជិះម៉ូតូជ្រែពីមុខម៉ូតូរបស់ខ្លួន ។ ពេលនោះខ្លួនបានជិះម៉ូតូធម្មតាទៅមុខរួចមិត្តភក្តិខ្លួនឈ្មោះ [redacted] រ៉ែន បានហូតខ្សែក្រវ៉ាត់វាយទៅលើបុរសនោះមួយខ្សែក្រវ៉ាត់មិនដឹងត្រូវចំណាទេ ហើយបុរសនោះបានវេចង្កូតម៉ូតូមករកម៉ូតូខ្លួន ខ្លួនក៏ជាក់ម៉ូតូបុរស

ម្នាក់នោះមួយជើងចំក្បាលម៉ូតូចូលទៅក្នុងរោងការគេតែម្តង។ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ន បានឆ្លើយថា៖ នៅថ្ងៃកើតហេតុ ខ្លួននិងឈ្មោះ [redacted] ប៉េងឡាត់ បានជិះម៉ូតូឌុបគ្នាដើម្បីទៅមើលល្ខោននៅវត្តទឹកវិល ពេលមកដល់ចំណុចកើតហេតុក៏មានម៉ូតូមួយគ្រឿងបើកបរដោយបុរសម្នាក់ បានជិះម៉ូតូគៀរម៉ូតូរបស់ខ្លួន ម្តងហើយម្តងទៀត ធ្វើឲ្យខឹងក៏បានហូតខ្សែក្រវ៉ាត់វាយទៅលើជននោះចំនួនមួយខ្សែក្រវ៉ាត់មិនដឹងត្រូវចំណាទេ ចំណែកឈ្មោះ ឡុង ប៉េងឡាត់ ក៏បានជួយធាក់ថែម០១ជើងទៀត ។ ឃើញថា ចម្លើយនេះគឺជនជាប់ចោទបានឆ្លើយសារភាពពីអំពើប្រព្រឹត្តល្មើសរបស់ខ្លួន ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុចម្លើយរបស់ជនរងគ្រោះ និងរបាយការណ៍របស់មន្ត្រីនគរបាល ។

៤-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡៃតិច បានបញ្ជាក់ថា៖ កាលពីថ្ងៃកើតហេតុ កូនប្រុសរបស់ខ្លួនឈ្មោះ តិច ប៉េងស៊ាង បានសុំខ្លួនទៅខាងក្រៅផ្ទះដើម្បីទិញម្ហូប បន្ទាប់មកបានប្រហែល១០នាទី មានមិត្តភក្តិកូនប្រុសខ្លួនបានមកប្រាប់ថា កូនប្រុសខ្លួនត្រូវគេវាយបែកក្បាល ។ ខ្លួនបានទៅដល់កន្លែងកើតហេតុហើយបានយកកូនប្រុសរបស់ខ្លួនទៅពេទ្យដើម្បីលាងរបួសនិងដេរចំនួន ៨ថ្នេរ ។ អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ប៉េងស៊ាង** បានបញ្ជាក់ថា៖ នៅថ្ងៃកើតហេតុ ខ្លួនបានជិះម៉ូតូទៅមើលល្ខោនតែម្នាក់ឯង ពេលជិះមកដល់ចំណុចរោងការអ្នកស្រុក បានឃើញឈ្មោះ [redacted] រ៉ន និងឈ្មោះ [redacted] ប៉េងឡាត់ ជិះម៉ូតូមកតាមក្រោយខ្លួនហើយបានធ្វើសកម្មភាពយកខ្សែក្រវ៉ាត់វាយខ្លួនត្រូវចំក្បាលបណ្តាលឲ្យចេញឈាម បន្ទាប់មកបានធាក់ម៉ូតូរបស់ខ្លួនមួយជើងផ្តួបចូលរោងការ ។ ឃើញថា ចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដែលជាភស្តុតាងមួយដាក់បន្ទុកទៅលើជនជាប់ចោទ ។

៥-ទាំងចម្លើយរបស់ជនជាប់ចោទ , អំណានចម្លើយរបស់ជនរងគ្រោះ , អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងរបាយការណ៍របស់មន្ត្រីនគរបាល ព្រមទាំងភស្តុតាងនានាដែលជាឯកសារពាក់ព័ន្ធមានភាពស៊ីសង្វាក់គ្នាដែលអាចកំណត់បានថា ជនជាប់ចោទពិតជាប្រព្រឹត្តបទល្មើសប្រាកដមែន ។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺមានចេតនាវាយតប់ទៅលើជនរងគ្រោះ បណ្តាលឲ្យជនរងគ្រោះរងរបួស ដែលអំពើនេះច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ និងមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

៧-ជនជាប់ចោទជានីតិជននិងអនីតិជន ដែលមិនមានភស្តុតាង ឬសញ្ញាណបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ លើអំពើប្រព្រឹត្តរបស់ខ្លួន។ អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយសាធារណៈ ដែលច្បាប់បានហាមឃាត់។

៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ប៉េងឡាត់** និងឈ្មោះ [redacted] **រ៉ន** ពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ។

៩-គប្បីតុលាការប្រកាស់ទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត ក្នុងកំរិតដាក់ពន្ធនាគា ១ឆ្នាំ និងឲ្យអនុវត្តទោសព្យួរធម្មតាមួយផ្នែក , ជនជាប់ចោទឈ្មោះ [redacted] រ៉ន ក្នុងកំរិតដាក់ពន្ធនាគា ៦ខែ ដោយពិចារណា ទៅលើភាពធ្ងន់ស្រាលនៃបទល្មើស និងសកម្មភាពល្មើសរបស់ជនជាប់ចោទដូចខាងក្រោម:



Scanned with CamScanner

-អំពើល្មើសរបស់ជនជាប់ចោទបានធ្វើឲ្យប៉ះពាល់ដល់ រូបរាងកាយរបស់អ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម។

-សកម្មភាពល្មើសពុំបង្កឲ្យមានព្យសនៈកម្មធ្ងន់ធ្ងរឡើយ។

-ជនជាប់ចោទបានឆ្លើយសារភាព ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ន គិតមកត្រឹមថ្ងៃប្រព្រឹត្តបទល្មើសគឺមានអាយុត្រឹមតែ១៦ឆ្នាំ ជាអនីតិជន ដោយយោងតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ អប្បបរមានិងអតិបរមានៃទោសត្រូវបន្ថយមកត្រឹមពាក់កណ្តាល ។ មូលហេតុទាំងនេះនាំឲ្យតុលាការ ពិចារណាប្រកាសទោសក្នុងកំរិតខាងលើដល់ជនជាប់ចោទ។

១០-ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារសំណងជំងឺផ្លូវចិត្ត និងថ្លៃព្យាបាលរបួសចំនួន ៦.០០០.០០០ (ប្រាំមួយលានរៀល) ឃើញថា បណ្តឹងនេះធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា១៣ , មាត្រា១៤ , មាត្រា១៥ , មាត្រា២១ និងមាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការអាចពិនិត្យនិងសម្រេចបានតាមមាត្រា២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តាមការពិនិត្យឃើញថា ការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមានចំនួនច្រើនដែលគប្បីតុលាការបន្ធូរបន្ថយឲ្យបានសមស្របទៅនឹងទំហំព្យសនៈកម្ម ជាក់ស្តែង។

១១-វត្ថុតាងរូមមាន៖ ខ្សែក្រវ៉ាត់ពណ៌ខ្មៅចំនួន ០១ខ្សែមានប្រវែង ១,០៤ ស.ម ក្បាលដែកពណ៌មាសមានរូបអក្សរ H ដែលជាមធ្យោបាយក្នុងការប្រព្រឹត្តល្មើស គប្បីសម្រេចរឹបអូស ។

១២-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីស្តាប់ការសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទបានឆ្លើយសារភាពទទួលនូវទង្វើប្រព្រឹត្តរបស់ខ្លួន ដែលបានប្រព្រឹត្តលើជនរងគ្រោះ។ ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទពីបទ៖ ហិង្សាដោយចេតនា តាមមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។ រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ៨៧៣ ដកសព ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល និងស្នើឲ្យតុលាការសម្រេចតាមច្បាប់។ គប្បីតុលាការពិចារណា ។

១៣-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ៖ ក្រោយពីបានសួរដេញដោលនាពេលសវនាការ កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពទទួលកំហុសរបស់ខ្លួន ដោយកូនក្តីខ្លួនជាអនីតិជន និងមានការយល់ដឹងនៅមានកំរិត ហេតុនេះស្នើសុំឲ្យតុលាការជួយបន្ថយទោសដល់កូនក្តីខ្លួន។ គប្បីតុលាការពិចារណា ។

១៤-សម្តីចុងក្រោយរបស់ជនជាប់ចោទ៖ ស្នើសុំតុលាការបន្ធូរបន្ថយទោស ។ គប្បីតុលាការពិចារណា។

**ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល**

**វិនិច្ឆ័យសេចក្តី**

**១-ផ្តន្ទាទោសជនជាប់ចោទ៖**

១.១-ឈ្មោះ [redacted] **ប៉េងឡាត់** ភេទប្រុស អាយុ ១៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted]ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ឡុង (រស់), ម្តាយឈ្មោះ [redacted] ឈឿន (រស់) នៅលីវ ទោសពីមុនគ្មាន។ (ឃុំខ្លួនថ្ងៃទី០៥/០៧/២២)

ដាក់ពន្ធនាគារកំណត់រយៈពេល ០១(មួយ)ឆ្នាំ តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ០៦(ប្រាំមួយ)ខែ ឯទោសសល់ពីនោះត្រូវអនុវត្តព្យួរធម្មតា ពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិ



Scanned with CamScanner

កោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ , មាត្រា១០៧ , មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ ។

១.២.ឈ្មោះ [redacted] រ៉ន **ហៅចុង** ភេទប្រុស អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មកររោងចក្រ មានទីលំនៅកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិកូនជ្រៃ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ពៅ (រស់), ម្តាយឈ្មោះ [redacted] សារ៉ែន (រស់) នៅលីវ ទោសពីមុន គ្មាន។ (ឃុំខ្លួនថ្ងៃទី០៥/០៧/២២)

ដាក់ពន្ធនាគារកំណត់រយៈពេល ០៦(ប្រាំមួយ)ខែ ពីបទ៖ ហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិកោះខែល ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៧ និងមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ។

**២**-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ប៉េងឡាត់ និងឈ្មោះ [redacted] រ៉ន ហៅចុង រួមជាមួយនឹងអាណាព្យាបាលរបស់ឈ្មោះ [redacted] រ៉ន ដែលមានសារតាជាតិដូចខាងលើ រួមគ្នាសងសំណងជំងឺចិត្តសរុបជាប្រាក់ចំនួន ៤.០០០.០០០៛ (បួនលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឡៃតិច ការទាមទារលើសពីនេះលើកចោល ។

**៣**-វត្ថុតាងរួមមាន៖ ខ្សែក្រវ៉ាត់ពណ៌ខ្មៅចំនួន ០១ខ្សែមានប្រវែង ១,០៤ ស.ម ក្បាលដែកពណ៌មាសមានរូបអក្សរ H បំផ្លាញចោល ត្រូវរឹបអូស ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ៣កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ធ្វើនៅកណ្តាល,ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២
**ក្រឡាបញ្ជី**

[redacted]

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]